# រឿង មហាចោរនៅទល់ដែន

## ភាគទី១៧

ពាត្រីកន្លងទៅ បុត្រីនាងនៅតែបាត់ដដែល។ ថ្ងៃមួយមកជំនួសរាត្រីសង្វេគនេះទៀត ស្រីនៅតែដើររកកូននាង ទឹកភ្នែកដែលហូរ ឈប់ហូរអស់រលីងនៅតែទឹកចិត្តទេដែលហូរត ទៅទៀត។ ថ្ងៃមួយទៀតកន្លងមក ពីរថ្ងៃទៀតកន្លងមក គ្មានលេចឮដំណឹងអ្វីមួយពីបុត្រ សង្សារនាងសោះ ឱ! ស្ងាត់អ្វីក៏ស្ងាត់ម្ល៉េះ ។ នាងទេវីអស់សង្ឃឹម។ នាងពុំដេកពួនសោះ។ ដោយអស់កំលាំងខ្លាំងពេក មាតាទុគ៌តចូលទម្រេតខ្លួនលើគ្រែប្របនាងក្នុងដែលអស់កំលាំង ដូចគ្នា។ កាលនាងនឹកដល់បុត្រី នាងឃើញមុខស្រីកល្យាណនៅតែនឹងភ្នែក មុខមូលក្រលង់ ញញឹមស្រស់ ។ ស្រីមើលទៅឆ្វេង ស្រមៃឃើញកូនកម្សត់មើលទៅខាងស្តាំឃើញរូបកូន មើលលើតុហាក់ឃើញកូន មើលគ្រប់ទិសឃើញកូនដរាប។ រូបកូនបែងចែកគ្រប់ទិសានុទិស។ ជីតាឈោងដៃចាប់ កូនថយទៅ។ នាងដើរតាម កូនថយទៅទៀត។ នាងថយមកវិញ កូនដើរតាមមក ។ ស្រីអង្គុយសំពះឲ្យកូន នៅស្ងៀមមួយកន្ទែង រួចសើចគ្រហាញមករកនាងវិញ។ ឱ! រកាំក្នុងចិត្តអ្វីម្ល៉េះទេ ជីតារមួលអស់ទាំងខ្លួន។ ទេវីជិតតែនឹងទៅជាឆ្កួតទៅហើយ។ កែវលក្ខណ៍ដើរមួយៗ ទៅយកកាំបិតស្នៀតមកកាន់បើបអាវុធពីក្រោមស្រោម ឱបអាវុធជាប់នឹងទ្រូង សើចដាក់អាវុធ រួចនាងយំដាក់អាវុធ រួចទឹកភ្នែកស្រក់តក់ៗ។ មួយៗ នាងហូតកាំបិតចេញពីស្រោម ។ នាងយកមេដៃស្ទាបមុខកាំបិត ។ នាងមើលចុងកាំបិត។ ឱ! កាំបិទមុត ៗ មែនចុងស្រួច។ ស្រីកម្សត់និយាយតិចៗថា៖

KHMER CIVILIZATION

- ថ្ងៃនេះ ខ្ញុំផុតអស់ទុក្ខហើយ ។ កាំបិតនេះហើយជាមិត្ត ជាទីអវសានរបស់ខ្ញុំ។ កាំបិតនេះជាថ្នាំដែលស្រាយចំណងខ្ញុំឲ្យមានសេរីភាពពិត។ ក្នុងវដ្តសង្សារ ។ ជីវិតមនុស្សហាក់វេទនាណាស់ មានតែទុក្ខ គ្មានសុខមែន!!

ជីតានឹកទៀតថា តើរស់នៅធ្វើអ្វី បើចិត្ត បើថ្លើមស្លាប់អស់ទៅហើយ។ ទេវីបើបចុងកាំបិទហាក់ដូចស្រលាញ់ណាស់។ នាងយកដៃបេះឡេវអាវ រួចមើលទៅចុងដងផ្ចឹមខ្លួន។ នាងយកចង្អុលដៃចុច ៗចុងដង្ហើមនាងនេះ ដើម្បីរកមើលកន្ទែងដែលចុងកាំបិតត្រូវលូកចូលទៅ។

អត្ថបទដោយ៖ មាស សុភាព

កញ្ញាលុតជង្គង់សំពះដល់ទេវតា សុំកុំឲ្យយកទោសនាង ៗនឹងសម្លាប់ខ្លួនក្នុងពេលនេះហើយ ។ ចុងកាំបិតក៏ចុចលើចុងដង្ហើមគ្មានបង្អង់។ ស្រីប្រាថ្នាថា កើតជាតិនានា កុំឲ្យមានទុក្ខដូចជាតិនេះទៀត។ កាំបិតស្មៀតរុញទៅមុខ ស្រាប់តែអ្នកស្រុកម្នាក់ស្ទុះចូលមកពីក្រោយនាងស្រែកយ៉ាងរីករាយថា៖

- ខ្ញុំទើបបានដំណឹងមួយថា លោកមេទ័ពមានន្ទពុំទាន់ស្លាប់ទេ នាងទេវីលួចលាក់កាំបិទដំមុតថ្វានោះ សៀតនៅចង្កេះបង្កប់ក្នុងអាវដែលនាងបិទឡេវវិញយ៉ាងស្រួលបួល។ កែវបែរយ៉ាងស្ងួតមករកពូនោះ៖
- ពូដឹងពីណាមក ?
- យី ! អាសូរវាមកដល់ហើយ។

នាងហាក់បានកើតម្តងទៀត ។ នាងសើចទាំងទឹកភ្នែក។

- កាលណាបានបងមកដល់ ?
- អាសូរវាថា បីថ្ងៃទៀត។
- ម្តេចបងមិនមកថ្ងៃនេះ ?
- ថាចាំរៀបទ័ពហែក្បួនឲ្យបានសង្ហាបន្តិច។
- ខ្ញុំត្រេកអរណាស់ពូ ! ឱ ! ពូអើយខ្ញុំផុតអស់ទុក្ខហើយ ប្អូនសូម . . . ឱ ! ពូអញ្ជើញទៅវិញហើយ ?
- បាទ ! ហេតុតែសំណាងនាង។
- ចាំះ ! អរគុណពូណាស់ អញ្ជើញចុះ។

នាងទេវី រីករាយយ៉ាងក្រៃលែងនឹងដំណឹងនេះ។ នាងរត់ទៅប្រាប់នាងក្លង់ ដែលអរ កខិបកខុប ។ នាងទៅមុជទឹកលុបលាងកាយ ដុសសាប៊ូ លាបល្មៀតយ៉ាងស្អាត។ បើជនណាដែលពុំស្គាល់នាង មុខជាចាត់ថានាងនៅក្រមុំមិនខាន។ ចំនួនយូរខែមកហើយ នាងពុំដែលតុបតែងខ្លួនសោះ។ ទើបតែថ្ងៃនេះនាងហៅយាយក្លង់សិតសក់នាង ឲ្យជួយលាបម្សៅនាង។ ធរីញញឹមដោយឃើញថា នាងនៅតែល្អស្រស់ដដែល។ សំណើចនាងធ្វើឲ្យឃើញធ្មេញសស្គុ

អត្ថបទដោយ៖ មាស សុភាព

សៗ ធីតាពាក់អាវល្អ សំពត់ល្អៗ នាងបេះផ្កាមកចងជាបូដាក់លើសក់ នាងប្រុងខ្លួនចាំទទួលប្តី ប្តីដែលនាងនឹកជាយូរមកហើយ ប្តីដែលជាគូកម្សត់ព្រាត់យូរថ្ងៃខែមកហើយ ប្តីដែលស្រលាញ់នាងវិញយ៉ាងពេញចិត្ត។

មាណវីនឹកថា ត្រូវនាងតុបតែងខ្លួន កុំឲ្យជុំឆ្អេះឆ្អាបទៅលើប្តីដែលរឭកនាងដែរ។ ឱ! បីថ្ងៃទៀត មុខជានាងបាននិត្យនៅជាប់នឹងដើមទ្រូងប្រុសសម្លាញ់នេះហើយ គឺនឹងបាននិយាយរៀបរាប់ប្រាប់ទុក្ខនាង ប្រាប់ការកំព្រាដែលនាងបានឆ្លងរួចមក ប្រាប់អំពីកំនើតបុត្រី ប្រាប់អំពីបុត្រី។ មកដល់ត្រង់នេះ នាងទេវីហូរទឹកភ្នែករហាមវិញ។ សេចក្តីសប្បាយទាំងប៉ុន្មានរត់ចេញអស់ពីចិត្តនាង។ សេចក្តីរីករាយរបស់នាងហាក់របេះមួយម្តងៗ ធ្លាក់ទៅក្នុងរណ្តៅជ្រៅមួយ។ ស្រីនឹកថា បើបុត្រីជាទីស្នេហានៅម៉្វេះ សមនឹងបានពបុត្រីនេះទៅបង្ហាញប្តី ឲ្យប្តីថើបបុត្រនេះផង។ តែឥឡូវ ដៃនាងទទេ ។ នាងហាក់ស្រាលខ្លួនស្ទើក។ ក្នុងពេញមួយថ្ងៃនេះ ធីតាប្រឹងរៀបចំផ្ទះសម្បែង បោសសំអាត ជុសលាងវត្ថុនានា ខាត់តុបតែងយ៉ាងឱឡារិក រួចចាត់ការទិញម្ហូបអាហារឆ្ងើនំ ទុកចាំប្តីមានទិញចានល្អៗ ទុកសម្រាប់ដាក់ឲ្យស្វាមីបរិភោគអាហារនិងទិញកន្ទេលថ្មីៗ ឲ្យអ្នកប្រុសសំរាន្ត។ ឱ !នាងចេះតែនឹកឃើញចំណុចឯទៀតៗ ជាច្រើនណាស់តែនាងពុំអាចធ្វើតាមចិត្តដែលនាងនឹកឃើញទាំងអស់នោះឡើយ ពីព្រោះស្រីក្រណាស់។ គំនិតនិមួយៗ ដែលដុះលេចឡើងក្នុងវិញ្ញាណរបស់នាងក្នុងមួយពេលនេះគឺដុះលេចមកឯងៗ រួចគំនិតនីមួយៗ ជាសន្តានចិត្តនាងដែលស្មោះចំពោះលើស្វាមី៕

(សូមរង់ចាំតាមដានភាគទី១៨ នៅសប្តាហ៍ក្រោយ)

អត្ថបទដោយ៖ មាស សុភាព